**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៦)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតដែលបានព្យួរកិច្ចសន្យាការងារក្នុងខែមិថុនា ខែកក្កដា និងខែសីហា ឆ្នាំ២០២៣ នៃរោងចក្រ ទាំង២២ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ នាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង២២ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០២៣

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០២៣
បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ
ចំនួន ២២ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 22 |
| 1 | ក្រុមហ៊ុន ភី ភី អេស អ៊ី ស៊ី ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន អ៊ីហ្ស៊ី ឡាហ្វ ស៊ូ អិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន អិកស៍អូថិច អ៊ិនជាសស្រៀល ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ឈុនឌីង ព្រីនធីង ខូអិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន សាន់តិច ភីធីអ៊ី អ៊ុលធីឌី | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ហូតាហ្វិតវែរ ឯ.ក | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ស៊ីកូ(ភ្នំពេញ)ខូអិលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុន អ៊ីស្ទេច ហ្គាមេន ខូអិលឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ប្រូដឡៃនខេមបូឌាហ្គាមែនអ៊ិនឌិសស្ទ្រី | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ជេ-កូវី បេស (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 11 | ក្រុមហ៊ុន ខេវីធី អ៊ីអឹមប៊ី បេស (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 12 | ក្រុមហ៊ុន បូវយើរ ហ្គាមេនហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីតធីត | កណ្តាល |
| 13 | ក្រុមហ៊ុន ខេមបូ យូនីសូល អិលធីឌី | កណ្តាល |
| 14 | ក្រុមហ៊ុន ដឹ សូល ហ្វៀ (ខេមបូឌា) ឯ.ក | កណ្តាល |
| 15 | ក្រុមហ៊ុន ឃៃ យ៉ាង ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 16 | ក្រុមហ៊ុន ហ្វ៊ូរឈូន ប្រត ហ្វ៊ុតវែរ ឯ.ក | កណ្តាល |
| 17 | ក្រុមហ៊ុន ថបហ្វម (ខេមបូឌា) មេនូហ្វេកឆឺរីង ឯ.ក | កណ្តាល |
| 18 | ក្រុមហ៊ុន ហ៊ុង ហ៊ឺង មេធល មេនូហ្វេធើរី (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន អៅដរ ហ្វៀ (ខេមបូឌា) ឯ.ក | តាកែវ |
| 20 | ក្រុមហ៊ុន វ៉ាយស៍ ស៊ីឌី ហ្វូដវែរ មេធៀរៀល (ខេមបូឌា) ឯ.ក | កំពង់ចាម |
| 21 | ក្រុមហ៊ុន អ៊ីលីត (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 22 | ក្រុមហ៊ុន ហ៊ែលសា សៅអ៊ិសអេស៊ា ខូអិលលធីឌី | ស្វាយរៀង |